Asia Pacific Leadership Forum on HIV & AIDS (APLF)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សុន្ទរកថា

របស់លោកជំទាវ កិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន

ឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកា ភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក

ចំពោះការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍ នៅកម្ពុជា

ឥស្សរជនឆ្នើមថ្នាក់ជាតិនៃផែនការសកម្មភាពរួម

អគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីសុខភាពស្ត្រី និងកុមារ

តំណាងដ៏ខ្ពង់ខ្ពស់

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ក្នុង ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ

**ក្រោមប្រធានបទ** " *ឈានឆ្ពោះទៅរកគ្មានការឆ្លងថ្មី គ្មានការរើសអើង គ្មានការស្លាប់* "

**សាលសន្និសីទចតុមុខ រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១**

- ***សូមគោរព ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិក-សមាជិកា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល គណៈអភិបាលរាជធានីភ្នំពេញ***
- ***លោក តូនី ឡាយ (Tony Lisle) អ្នកសម្របសម្រួលអង្គការយូអិនអេដស៍ប្រចាំកម្ពុជា***
- ***ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត***

- ***ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ ជាទីមេត្រី***
- ***លោកគ្រូ អ្នកគ្រូ ក្មួយៗ សិស្ស និស្សិត យុវជនកាកបាទក្រហមកម្ពុជា ទាំងអស់ ជាទីស្រឡាញ់ !***

ថ្ងៃនេះ ខ្ញុំ មានកិត្តិយស និង ក្តីសោមនស្សរីករាយ ដោយបានមកចូលរួមជាតំណាងដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីប្រារព្ធ **ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ឆ្នាំ ២០១១** ដែលជាការបង្ហាញ អំពីការប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នា ក្នុងការបន្តចូលរួម ក្នុងយុទ្ធនាការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ជំងឺអេដស៍ ក្រោមប្រធានបទ" **ឈានឆ្ពោះទៅរកគ្មានការឆ្លងថ្មី គ្មានការរើសអើង គ្មានការស្លាប់** " ។

ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមសម្តែងនូវអំណរសាទរ ការកោតសរសើរ និង ការវាយតម្លៃខ្ពស់ ចំពោះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ស្ថាប័ន អង្គភាពពាក់ព័ន្ធ កាកបាទក្រហមកម្ពុជា សហគមន៍អន្តរជាតិ សង្គមស៊ីវិល វិស័យឯកជន និង បង-ប្អូនប្រជាពលរដ្ឋ ដែលបានខិតខំប្រឹងប្រែង ក្នុងការទប់ស្កាត់ និង ប្រយុទ្ធប្រឆាំងនឹងការរីករាលដាលជំងឺអេដស៍ រហូតសម្រេចបានជោគជ័យ គួរជាទីមោទនៈ ដោយកាត់បន្ថយបាននូវការចម្លងមេរោគអេដស៍ថ្មីៗបន្ថែមទៀត ការបង្កើននូវការថែទាំព្យាបាល ការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ ការបង្កើននូវការផ្តល់ការថែទាំសុខភាពសង្គមដល់កុមារកំព្រា និង កុមារងាយរងគ្រោះ ដោយសារជំងឺអេដស៍។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាយើង នៅតែអាចគ្រប់គ្រងបានប្រកបដោយប្រសិទ្ធភាព នូវស្ថានភាពនៃការទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ មិនឱ្យកើនឡើងទៀតបាន។ យើងអាចធ្វើឱ្យអាត្រាឆ្លងរាលដាល ថយចុះពី ២% នៅឆ្នាំ ១៩៩៨ មកនៅត្រឹម ០.៨% ក្នុងឆ្នាំ ២០១០ គិតក្នុងចំណោមប្រជាពលរដ្ឋ អាយុ ១៥-៤៩ ឆ្នាំ ដែលតួលេខនេះ បានទទួលការសរសើរពីសំណាក់អង្គការសហប្រជាជាតិ ព្រមទាំងពានរង្វាន់ ក្នុងការធ្វើសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍ទី ៦ នាឆ្នាំ ២០១៥ ខាងមុខនេះ ។

ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១១ នេះ គឺជា ការប្រារព្ធ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ លើកទី ២២ នៅលើសកលលោក និងជាលើកទី ១៩ ហើយ ដែលព្រះរាជាណាចក្រកម្ពុជា បានចូលរួមជាមួយពិភពលោកទាំងមូល ក្នុងការប្រារព្ធទិវាដ៏មានអត្ថន័យនេះ និងជាឱកាសសម្រាប់ការជួបជុំ គ្រប់មជ្ឈដ្ឋានជាតិ-អន្តរជាតិទូទាំងប្រទេស ធ្វើការចែករំលែកព័ត៌មាន ជំនាញ និងបទពិសោធន៍ថ្មីៗ ស្តីពីប្រសិទ្ធភាពនៃការទប់ស្កាត់ ការរីករាលដាលនៃមេរោគអេដស៍ និង ការថែទាំព្យាបាល។ ទន្ទឹមនឹងនេះ ក៏ជាការសំដែងនូវការគាំទ្រដល់ អ្នកផ្ទុកមេរោគអេដស៍ និង ជំងឺអេដស៍ ឱ្យខិតខំតស៊ូរស់នៅតទៅទៀត នៅក្នុងសង្គមជាតិមួយ ដែលផ្តល់ឱ្យជានិច្ច នូវភាពកក់ក្តៅ និងសេចក្តីស្រឡាញ់។ លើមូលដ្ឋាននៃការពង្រឹង ចំណងសាមគ្គីភាពជាតិ-អន្តរជាតិ ក្នុងការប្រយុទ្ធ

នឹងជំងឺអេដស៍ជាបន្តទៅទៀត ដែលជាពិសេស ចាប់ពីឆ្នាំនេះតរៀងទៅ គឺ ការលើកកម្ពស់ស្មារតី ចូលរួមអនុវត្តសេចក្តីថ្លែងការណ៍ ស្តីពី " ការប្តេជ្ញាចិត្ត ប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈ **យុទ្ធសាស្ត្រសូន្យបី របស់អង្គការសហប្រជាជាតិ "** ដែលបានអនុម័តដោយរដ្ឋជាសមាជិក ក្នុងនោះរួមទាំង ព្រះរាជាណាចក្រកម្ពុជាផងដែរ។

*ឯកឧត្តម លោកឧកញ៉ា លោកជំទាវ*
*អស់លោក លោកស្រី និង អង្គពិធីទាំងមូល ជាទីមេត្រី !*

ក្នុងបុព្វហេតុជម្រុញការចូលរួម និងការគាំទ្រ ដើម្បីបង្កើតបានជាកម្លាំងចលករជាតិដ៏ធំមួយ ក្នុងការប្រយុទ្ធទប់ទល់ នឹងការចម្លង ការរីករាលដាលនៃមេរោគអេដស៍នៅកម្ពុជា តាម **យុទ្ធសាស្ត្រសូន្យបី** របស់អង្គការសហប្រជាជាតិ " ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាព ជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតប មេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា ខ្ញុំ សូមលើកឡើង នូវអនុសាសន៍ មួយចំនួន ជូនចំពោះបង-ប្អូន ជនរួមជាតិកម្ពុជា ទាំងអស់ ដូចតទៅនេះ:

**ទី១.** ទោះបីជាយើង ទទួលបានជោគជ័យជាបន្តបន្ទាប់ លើការទប់ស្កាត់ការរាលដាលមេរោគអេដស៍ ដែលគួរជាទីមោទនៈនេះក៏ដោយ ក៏យើងត្រូវតែរួមគ្នាខិតខំប្រឹងប្រែងឱ្យបានកាន់តែខ្លាំងក្លាបន្ថែមទៀត ដើម្បីកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ឱ្យបាន ៥០% ក្នុងចំណោមក្រុមដែលប្រឈមមុខខ្ពស់ ដូចជា ក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ក្រុមបុរសស្រឡាញ់បុរស និង ក្រុមយុវវ័យ ជាដើម នឹងឈានទៅកាត់ផ្តាច់ទាំងស្រុង នូវការចម្លងមេរោគអេដស៍ ពីម្តាយទៅកូន នៅឆ្នាំ ២០១៥។

**ទី២.** ថ្នាក់ដឹកនាំគ្រប់ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ទាំងអស់ បង្កើនការយកចិត្តទុកដាក់ និង ការទទួលខុសត្រូវឱ្យបានខ្ពស់ថែមទៀត ក្នុងការរិះរកគ្រប់មធ្យោបាយ គ្រប់លទ្ធភាព ទាំងធនធាន ទាំងថវិកាជាពិសេសត្រូវយកបញ្ហាអេដស៍ បញ្ច្រាប និង បញ្ចូលទៅគ្រប់សេវាទាំងអស់ នៅក្នុងស្ថាប័ន និងសហគមន៍ និង ត្រូវបន្តផ្សព្វផ្សាយចលនានេះ ឱ្យបានកាន់តែទូលំទូលាយ និង ឱ្យបានជាប់ជាប្រចាំ នូវចំណេះដឹង និង ព័ត៌មានស្តីពីមេរោគអេដស៍ ជំងឺអេដស៍ ឱ្យបានដល់គ្រប់មជ្ឈដ្ឋានប្រជាជនទាំងអស់ជាពិសេស នៅតាមតំបន់ដាច់ស្រយាល។

**ទី៣.** ត្រូវធានាឱ្យមានសុវត្ថិភាព ក្នុងការការពារនូវការចម្លងមេរោគអេដស៍ គ្រប់ទីកន្លែង និងគ្រប់កាលៈទេសៈ ដោយត្រូវបន្តរួមគ្នាជួយលើកកម្ពស់ការគោរពសីលធម៌ អរិយធម៌ និង ប្រពៃណី ទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ខ្មែរយើង ត្រូវស្រឡាញ់ស្មោះត្រង់ ប្តីមួយ ប្រពន្ធមួយអស់មួយជីវិត និង ត្រូវបន្តការលើកកម្ពស់យន្តការយេនឌ័រ និង ជំងឺអេដស៍ តាមរយៈការលើកកម្ពស់សិទ្ធិអំណាច និង ការផ្តល់ឱកាសឱ្យស្ត្រី និង កុមារីក្នុងការចូលរួមទប់ស្កាត់ការរាលដាលមេរោគអេដស៍ ជាពិសេស នៅក្នុងរង្វង់គ្រួសារ និង សង្គមទាំងមូល។

**ទី៤.** រាល់ការងារប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ត្រូវឆ្លើយតប ឱ្យបានទូលំទូលាយ និងមានលក្ខណៈ ជាពហុវិស័យ ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស សមធម៌ យេនឌ័រ និង គ្មានការរើសអើង។ ក្នុងន័យនេះ ខ្ញុំ សូមសង្កត់ធ្ងន់ថា អ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺអេដស៍ ពុំមែនជាឧក្រិដ្ឋជននោះទេ ផ្ទុយទៅវិញ អ្នកទាំងអស់នោះ គឺជាជនរងគ្រោះ ដែលត្រូវទទួលបាននូវសេវា បង្ការ ថែទាំ និង ព្យាបាល ដើម្បីរួចចាកផុតពី ការប្រឈមមុខនឹងការឆ្លង ការចម្លងមេរោគអេដស៍ ការរើសអើង និង ការមាក់ងាយ។ ជាមួយគ្នានេះ ខ្ញុំ សូមបញ្ជាក់ថា ការធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយបង្ខំ ឬ ដោយការតម្រូវ ត្រូវតែហាមឃាត់ជាដាច់ខាត ព្រោះទង្វើនេះ គឺជា អំពើខុសច្បាប់។ អាជ្ញាធរមានសមត្ថកិច្ច និង អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ត្រូវចាត់វិធានការតាមច្បាប់ ដើម្បីផ្តន្ទាទោសចំពោះជនណា ស្ថាប័នណា ឬ អង្គភាពណា ដែលបានប្រព្រឹត្តល្មើសនឹង គោលការណ៍ច្បាប់ខាងលើនេះ។

**ទី៥.** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តបេសកកម្មដ៏ថ្លៃថ្លានេះ ក្នុងនាមជាស្ថាប័នដឹកនាំ គ្រប់គ្រង និង សម្របសម្រួលកម្រិតជាតិ ជំនួសរាជរដ្ឋាភិបាល ក្នុងការតាមដាន នូវការរាលដាលមេរោគអេដស៍ និង ការឆ្លើយតបទៅនឹងជំងឺអេដស៍ តាមរយៈគោលការណ៍ភាពជាម្ចាស់ ភាពសមស្របទៅតាមគោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និង ប្រកបដោយសុខដុមនីយកម្ម ក្នុងចំណោមដៃគូអភិវឌ្ឍទាំងអស់។

*ឯកឧត្តម លោកជំទាវ លោកឧកញ៉ា*

*អស់លោក លោកស្រី អង្គពិធីទាំងមូល ជាទីមេត្រី*

ពីលើវេទិកានៃការប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ នាពេលនេះ ជាថ្មីម្តងទៀត ខ្ញុំ សូមអំពាវនាវឱ្យសង្គមជាតិយើងទាំងមូល បង្កើនការប្តេជ្ញាចិត្តទ្វេដងថែមទៀត ដើម្បីចូលរួមជំរុញ ពង្រឹង និង ប្រយុទ្ធទប់ស្កាត់ ការឆ្លងមេរោគអេដស៍ ដោយអនុវត្តឱ្យមានប្រសិទ្ធភាពនូវសេចក្តីថ្លែងការណ៍ របស់អង្គការសហប្រជាជាតិ ក្នុងកិច្ចប្រជុំកំពូលនៃមហាសន្និបាតវិសាមញ្ញលើកទី ៦៥ កាលពីខែមិថុនា ឆ្នាំ២០១១ កន្លងទៅថ្មីៗនេះ និង សាររបស់ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា ផ្ញើជូនបង-ប្អូន ជនរួមជាតិ ក្នុងឱកាសទិវាពិភពលោក ប្រយុទ្ធនឹងជំងឺអេដស៍ ១ ធ្នូ ២០១១ នេះ ដែលមានគោលដៅ សម្រេច ឱ្យបានតាមពាក្យស្លោក " **ឈានឆ្ពោះ ទៅរក គ្មានការឆ្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់** "។ ខ្ញុំ មានជំនឿយ៉ាងមុតមាំថា យើងពិតជានឹងអាចធ្វើបាន ដោយ ចាប់ផ្តើមចេញពីជោគជ័យដែលយើងទទួលបានកន្លងមក និង ប្រមូលផ្តុំនូវគ្រប់កម្លាំងសារុបទាំងអស់របស់យើង ដើម្បីជំនះឱ្យបាននូវឧបសគ្គនានា ដែលនៅសេសសល់ និង ដោយឈរលើស្មារតីសាមគ្គីភាព ឯកភាពជាតិ ភាពជាដៃគូ និង សុខដុមនីយកម្ម ដើម្បីសេចក្តីថ្លៃថ្នូររបស់មនុស្ស ក្នុងការរស់នៅ និង ធ្វើការងារប្រកបដោយសុខភាព និង ចៀសវាងបានពីជំងឺអេដស៍ ។ ខ្ញុំ ហ៊ានអះអាង ប្រកបដោយជំនឿថា គ្មានអ្វី ដែលយើងធ្វើ មិនបាននោះទេ ប្រសិនបើ

យើង ឯកភាពគ្នា ក្នុងការធ្វើ និង ទាំងអស់គ្នាចូលរួមធ្វើ។ ក្នុងន័យនេះ ក្នុងនាមជា តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ក្នុងនាមកាកបាទក្រហមកម្ពុជា ព្រមទាំង ក្នុងនាមជា ឥស្សរជនឆ្នើមថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់ អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគ អេដស៍ជំងឺអេដស៍ និងជាឥស្សរជនឆ្នើមថ្នាក់ជាតិនៃផែនការសកម្មភាពរួម អគ្គលេខាធិការ អង្គការសហប្រជាជាតិ ដើម្បីសុខភាពស្ត្រី និង កុមារ ខ្ញុំ សូមប្រកាសចេញ នូវការប្ដេជ្ញាចិត្តរបស់កម្ពុជា ក្នុងការបន្តបេសកកម្មមនុស្សធម៌ ដ៏វិសេសវិសាលនេះ ឱ្យបានកាន់តែខ្លាំងក្លាថែមទៀត ដើម្បីឈានទៅសម្រេចឱ្យបាននូវសង្គមកម្ពុជាមួយ ដែល គ្មានការឆ្លងមេរោគអេដស៍ថ្មី គ្មានការស្លាប់ដោយសារជំងឺអេដស៍ និង គ្មានការរើសអើង ចំពោះអ្នកផ្ទុកមេរោគ អេដស៍ និង ជំងឺអេដស៍ និងជាពិសេស គឺការកាត់បន្ថយឱ្យបានទាំងស្រុង នូវភាពងាយរងគ្រោះរបស់ស្ត្រី និង កុមារី ទៅនឹងមេរោគអេដស៍។

ខ្ញុំ សូមអំពាវនាវ ចំពោះ អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍ អ្នកផ្ទុកមេរោគអេដស៍ និង អ្នកជំងឺ អេដស៍ទាំងអស់ សូមបន្តចូលរួមឱ្យបានកាន់តែខ្លាំងក្លាថែមទៀត តាមគ្រប់រូបភាព ទាំងកម្លាំងកាយ ប្រាជ្ញា ស្មារតី និង ថវិកា ដើម្បីពង្រីកអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព និង កាន់តែទូលំទូលាយថែមទៀត ដើម្បីឈានទៅសម្រេចបាន នូវអត្រាគ្របដណ្ដប់លើគ្រប់ភូមិសាស្ត្រ គ្រប់ក្រុមគោលដៅ និង គ្រប់សេវា ផងដែរ។

ទន្ទឹមគ្នានេះ ក្នុងនាម**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ខ្ញុំ សូមប្រកាសជាឧឡារិកថា រាជរដ្ឋាភិបាលកម្ពុជានៅតែចាត់ទុកបញ្ហាអេដស៍ ជាបញ្ហាអាទិភាពខ្ពស់ ដោយបានដាក់បញ្ចូលរួចជាស្រេច ទៅក្នុង គម្រោងអភិវឌ្ឍជាតិជាអាទិភាព ឆ្នាំ ២០១១-២០១៣ និង បន្តជួយគាំទ្រ តាមគ្រប់រូបភាព ទាំង ក្នុងក្របខ័ណ្ឌ គោលនយោបាយ និង យុទ្ធសាស្ត្រ ដើម្បីដឹកនាំឱ្យមានបរិយាកាសវិជ្ជមានដល់ប្រតិបត្តិករ និង សកម្មជនប្រយុទ្ធ នឹងជំងឺអេដស៍ទាំងអស់ ជាពិសេស គឺការបន្តការបង្កើនថវិកាជាតិ ទៅតាមលទ្ធភាព ដែលរាជរដ្ឋាភិបាលអាចធ្វើ ទៅបានដែលនេះ ជាការចូលរួមជាមួយ ពិភពលោកទាំងមូល ក្នុងការអនុវត្ត **យុទ្ធសាស្ត្រសូន្យបី** ដើម្បីកាត់ផ្ដាច់ បានទាំងស្រុង នូវការចម្លងមេរោគអេដស៍ នៅឆ្នាំ ២០២០។

ក្នុងឱកាស ដ៏ឧត្ដុង្គឧត្ដមនេះ ខ្ញុំម្ចាស់សូមបួងសួង ដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ព្រមទាំង ព្រះវិញ្ញាណក្ខ័ន្ធ នៃ អតីតព្រះមហាក្សត្រ គ្រប់ព្រះអង្គសូមប្រស់ព្រំ ថែរក្សា **ព្រះករុណា ព្រះបាទ សម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា **ព្រះករុណា ព្រះមហាវីរៈក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និង **សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ព្រះប្រធានកិត្តិយស កាកបាទក្រហមកម្ពុជា ជាទីគោរពសក្ការៈ ដ៏ខ្ពង់ខ្ពស់បំផុត សូមមានព្រះរាជសុខភាពល្អបរិបូណ៌ និង ព្រះជន្មាយុយឺនយូរ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ដល់ ប្រជារាស្ត្រគ្រប់រូប ជាកូនចៅ ចៅទួត របស់ព្រះអង្គ រៀងដរាបតទៅ។

នៅទីបញ្ចប់នេះ ខ្ញុំព្រះករុណា ខ្ញុំ សូមប្រគេនពរ ព្រះតេជគុណព្រះសង្ឃ គ្រប់ព្រះអង្គ និង សូមជូនពរ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ ឯកអគ្គរាជរដ្ឋ ឯកអគ្គរដ្ឋទូត អង្គទូត ភ្ញៀវជាតិ និង អន្តរជាតិ អស់លោក លោកស្រី លោកគ្រូ អ្នកគ្រូ ក្មួយៗ សិស្ស និស្សិត យុវជនកាកបាទក្រហមកម្ពុជា សូមមាន សុខភាពល្អបរិបូណ៌ និង សម្រេចបាន នូវជោគជ័យថ្មីៗថែមទៀត នាឆ្នាំខាងមុខនេះ និងសូមប្រកាសជាឱឡារិក ថា **កម្ពុជាប្តេជ្ញា ធ្វើដំណើរឆ្ពោះទៅរក គ្មានការចម្លងថ្មី គ្មានការរើសអើង គ្មានការស្លាប់ ដោយសារមេរោគអេដស៍ ។**

*សូមអរព្រះគុណ និង អរគុណ!*